ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Aug-2015, 15:06
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**
**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវុឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

# សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រសម្រាប់សំណើទីប្រាំមួយស្តីពីការ ដាក់ភស្តុតាងបន្ថែមដែលនឹងស្នើឡើងនៅពេលខាងមុខ

**សហព្រះរាជអាជ្ញា** **សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង

Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

សុន អរុណ

Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“**អង្គជំនុំជម្រះតុលាការកំពូល**” និង“**អ.វ.ត.ក**”),

**បានទទួល** “សំណើបន្ទាន់របស់ នួន ជា សុំបន្ថែមចំនួនទំព័រលើសំណើលើកទីប្រាំមួយរបស់ខ្លួនដែលនឹងដាក់ក្នុងពេលឆាប់ៗសុំឱ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១” (“សំណើសុំ”)[1],

**កត់សម្គាល់ឃើញ**ថា នួន ជា បញ្ជាក់ថា ខ្លួន មានបំណងដាក់សំណើសុំលើកទីប្រាំមួយស្តីពីការដាក់ភស្តុតាងបន្ថែម និងស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល បន្ថែមចំនួន ៣០ ទំព័រទៀត សម្រាប់សំណើនេះ ដែលលើសពីការកំណត់នៅក្នុងមាត្រា ៥.២ នៃសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារ ដែលកម្រិតត្រឹម ៣០ ទំព័រ[2] ហើយ នួន ជា បានអះអាងថា “កាលៈទេសៈពិសេស”តម្រូវឱ្យអនុវត្តតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[3],

**កត់សម្គាល់ឃើញ**ថា នួន ជា បានលើកឡើងថា កាលៈទេសៈពិសេស ដែលតម្រូវឱ្យមានការបន្ថែមចំនួនទំព័រនោះគឺ (១)“ចំនួន និងភាពស្មុគស្មាញនៃព័ត៌មាន”ដែលត្រូវបញ្ចូលទៅក្នុងសំណើសុំ[4] (២)អត្ថប្រយោជន៍ក្នុងការជំរុញនូវប្រសិទ្ធិភាពរបស់តុលាការ ដោយបានបញ្ចូលសំណើបីដាច់ដោយឡែកពីគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាយ៉ាងមានប្រសិទ្ធិភាព ទៅជាសំណើតែមួយ[5] និង(៣) ភាពចាំបាច់ក្នុងការបង្ហាញឯកសារដែលងាយយល់ និងមានអត្ថន័យ ដែលត្រូវបានស្នើឡើងជាភស្តុតាងបន្ថែម ដែលតម្រូវឱ្យមានសេចក្តីសង្ខេប និងព័ត៌មានសវតារនៅក្នុងសំណើនោះ[6]។

---

[1] ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ F27។

[2] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ឯកសារលេខ ECCC/01/2007/វិ. លើកទី ៨ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ (“សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ”)។

[3] សំណើ កថាខណ្ឌនៃសេចក្តីផ្តើម និងកថាខណ្ឌ ៣ និង៩។ ទោះបីជាពុំមានការលើកឡើងឱ្យបានជាក់លាក់នៅក្នុងសំណើក៏ដោយ ក៏បានបង្ហាញច្បាស់លាស់ក្នុងបរិបទនេះថា សំណើនេះសំដៅលើការកម្រិតចំនួនទំព័រទាក់ទងនឹងការដាក់ឯកសារជាភាសាអង់គ្លេស និងបារាំង ហើយបន្ថែមចំនួនទំព័រដែលសមមាត្រទៅនឹងឯកសារជាភាសាខ្មែរ។

[4] សំណើសុំកថាខណ្ឌ ៥។

[5] សំណើសុំកថាខណ្ឌ ៤ និង ៦។

[6] សំណើសុំកថាខណ្ឌ ៧ និង ៨។

**ដោយពិចារណាឃើញ**ថា ដោយហេតុថា វិសាលភាពនៃសំណើមានកម្រិត និងមានលក្ខណៈសាមញ្ញ ដូចនេះ ការចេញសេចក្តីសម្រេចបច្ចុប្បន្ននេះ ដោយពុំចាំបាច់រង់ចាំរហូតដល់កាលបរិច្ឆេទសម្រាប់ដាក់សារណាតបទៅនឹងសំណើនេះ គឺផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់តុលាការ,

**រំលឹក**ថា មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ កម្រិតត្រឹម ៣០ ទំព័រចំពោះឯកសារដែលដាក់ជាភាសាអង់គ្លេស ឬបារាំង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល លើកលែងតែមានបទប្បញ្ញត្តិចែងផ្ទុយពីនេះ,

**រំលឹក**ថា មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារបានអនុញ្ញាតឱ្យអង្គជំនុំជម្រះពាក់ព័ន្ធបន្ថែមចំនួនទំព័រដែលបានកំណត់នេះ ដោយតម្រូវឱ្យភាគីដែលស្នើសុំបន្ថែមនោះ ត្រូវបង្ហាញនូវអត្ថិភាពនៃកាលៈទេសៈពិសេស,

**ដោយពិចារណាឃើញ**ថា ការកំណត់ចំនួនទំព័រ "ទោះបីជាចាំបាច់យ៉ាងណាក៏ដោយ ត្រូវតែសម្របសម្រួលទៅតាមតម្រូវការចាំបាច់របស់ភាគី ដើម្បីឱ្យមានតុល្យភាពជាមួយនឹងគោលការណ៍សំខាន់ស្តីពីប្រសិទ្ធិភាពរបស់តុលាការ"[7] និងថា ទាក់ទងបញ្ហានេះ ភាគីដែលស្នើសុំ ត្រូវលើកឡើងនូវ"មូលហេតុត្រឹមត្រូវ" ដោយធ្វើការបង្ហាញពី"ផលប្រយោជន៍ផ្នែកច្បាប់ច្បាស់លាស់" ទើបធានាបានការបន្ថែមចំនួនទំព័រដែលស្នើសុំនោះ[8],

**ដោយពិចារណាឃើញ**ថា សេចក្តីសម្រេចពីមុនលើសំណើសុំបន្ថែមចំនួនទំព័រ បានផ្តល់ការអនុញ្ញាតឱ្យធ្វើដូច្នេះ ដោយផ្អែកលើទំហំ និងភាពស្មុគស្មាញនៃសំណើរបស់ភាគីដែលស្នើសុំដាក់ឆាប់ៗខាងមុខ ដែលជាមូលហេតុត្រឹមត្រូវស្របទៅតាមលក្ខណៈវិនិច្ឆ័យនៃមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់

---

[7] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រលើបណ្តឹងសាទុក្ខ និងពេលវេលាធ្វើការឆ្លើយតប ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ F13/2 កថាខណ្ឌ ១៥។

[8] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ F3/3 ("សេចក្តីសម្រេចបន្ថែមពេលវេលា និងទំព័រ"), កថាខណ្ឌ ១០។

ឯកសារ ដោយពិចារណាលើភាពជាន់គ្នាជាមួយនឹងសំណើសុំដទៃទៀត និងតម្រូវការក្នុងការធានាឱ្យដំណើរការនៃការដាក់សារណាបានឆាប់រហ័ស និងមានអត្ថន័យគ្រប់គ្រាន់[9],

**ដោយពិចារណាឃើញ**ថា ក្នុងរឿងក្តីបច្ចុប្បន្ន នួន ជា បានបង្ហាញពីអត្ថប្រយោជន៍ផ្នែកច្បាប់ច្បាស់លាស់សម្រាប់ការបន្ថែមចំនួនទំព័រដែលបានលើកឡើងខាងលើ ចំពោះសំណើសុំខាងមុខរបស់គាត់ ហើយបានបំពេញទៅតាមលក្ខណៈវិច្ឆន័យនៃមាត្រា ៥.៤ ចែងអំពីសេចក្តីណែនាំការអនុវត្តស្តីពីការដាក់ឯកសារ។

## អាស្រ័យហេតុនេះ៖

**សម្រេច** ទទួលយកសំណើសុំនេះ,

**អនុញ្ញាត** ឱ្យ នួន ជា ដាក់សំណើរបស់ខ្លួនសរុបចំនួន ៦០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ដោយសមមូលជាមួយនឹងភាសាខ្មែរ សម្រាប់សំណើដែលបានស្នើសុំដាក់នៅពេលខាងមុខនេះ ស្តីពីការដាក់ភស្តុតាងបន្ថែម។

.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[9] សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ២២។ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ១៣។ សេចក្តីសម្រេចបន្ថែមចំនួនទំព័រ និងពេលវេលា កថាខណ្ឌ ១០។